# ការសម្ភាសន៍របស់ ជង់ គីមហួរ

**កៈ អ្នកសម្ភាសន៍ឈ្មោះ ជាង ស៊ីអ៊ាវ          ខៈ អ្នកទទួលការសម្ភាសន៍ឈ្មោះ ជង់ គីមហួរ**

កៈ ថ្ងៃនិងជា ថ្ងៃទី២ខែមិនាឆ្នាំ២០១៦ ចឹងខ្ញុំបាទឈ្មោះ ជាង ស៊ីអ៊ូវ ហើយខ្ញុំមកសួរអំពីពត៍មាន ខ្លះៗចឹងមីង ឈ្មោះពេញរបស់អ្នកមីង មានឈ្មោះអ្វីដែល?

ខៈ ជង់ គីមហួរ ។

កៈ ជង់ គីមហួរ អើ! មីងដឹងពីថ្ងៃខែឆ្នាំកំណើតមីង ហើយនិងមីង ប៉ុន្តែឥលូវនិងមីងមានអាយុប៉ុន្មានហើយមីង?

ខៈ អាយុ៥៦។

កៈ អូ!៥៦ ចាស់ដែលហើយ។

ខៈ ៥៦ ចាស់ហើយ។

កៈ រួចទៅមីង ទីកំណើតអ្នកមីង កើតនៅណាវិញមីង?

ខៈ កើតនៅព្រៃវែង។

កៈ ព្រៃវែងនោះ?

ខៈ នឹងហើយ។

កៈ ភូមិឃុំមីងចាំអត់?

ខៈ ភូមិព្រែកកាំភ្លើង ឃុំកំពង់អំពិល ស្រុកពារាំង ខេត្តព្រៃវែង។

កៈ ចុះមីងមានកូនប៉ុន្មានអ្នក មីង?

ខៈ កូន៤!

កៈ កូន៨! ចុះប្តីមីងឈ្មោះអ្វីគេវិញ?

ខៈ ប្តីរាល់ថ្ងៃនិងឈ្មោះ រី។

កៈឈ្មោះ រី នោះ!

ខៈចាំ!

កៈ អូ! ប៉ុន្តែមីងដឹង នៅណា គាត់កើតនៅណា?

ខៈ គាត់នៅពោធិ៍សាត់ ។

កៈ គាត់នៅខាងពោធិ៍សាត់ ?

ខៈ ចាំ!

កៈ អូ! ចុះកូនអ្នកមីង៨នាក់ឈ្មោះអ្វីគេវិញ មីង?

ខៈ មួយឈ្មោះ សុខ ខេង។

កៈ សុខ ខេង!

ខៈ មួយទៀតឈ្មោះ សុខ ខា មួយទៀតឈ្មោះ រដ្ឋា មួយទៀតចាន់ដា។

កៈ អូ! ចាន់ដាពៅគេ ?

ខៈ នឹងហើយ!

កៈ ចុះក្រុមគ្រួសារមីង នៅជុំគ្នា ឬមួយក៏មាន?

ខៈ រាល់ថ្ងៃ អត់ជុំគ្នាផង បែកគ្នាកូនវានវាបែកទៅរស់នៅរៀងៗ ខ្លួនទៅ។

កៈ អូ! គាត់រៀបការហើយ?

ខៈ គេមានកូនមានចៅអស់ហើយនឹង ។

កៈ អ៊ូ!

ខ៖ មានប្រពន្ធ មានកូន។

ក៖ នៅតែចាន់ដា?

ខ៖ នៅតែចាន់ដាមួយ។

ក៖ អ៊ូ! ចុះប្តីមីង?

ខ៖ គាត់ទៅធ្វើការបាត់ហើយ។

ក៖ គាត់ទៅធ្វើការ គាត់ធ្វើការអីគេវិញមីង?

ខ៖ គាត់ធ្វើទាហាន។

ក៖ ធ្វើទាហានៀនោះ?

ខ៖ ចាំ!

ក៖ ចុះមីងសព្វថ្ងៃ មីងធ្វើអីគេវិញមីង?

ខ៖ រាល់ថ្ងៃនៅផ្ទះលក់ដូរតិចតួច។

ក៖ អូ! លក់ដូរតិចតួច ខ្ញុំចង់សួរពីប្រវត្តិមីងខ្លះៗ។ កាលមីងនៅតូច មីងធ្លាប់ជួបទុក្ខលំបាក់អីខ្លះ?ហើយមីងបានចូលរៀន? ហើយមីង ដូចជាមីងនៅណា? ហើយកាលជំនាន់ប៉ុលពត មីងជួបបញ្ហាអីខ្លះកើតឡើង?

ខ៖ បើនិយាយកាលពីនូវតូច ធំឡើង។ កាលនូវតូចនិងធម្មតាទេ នូវជាមួយម៉ែឪនិងធម្មតាទេ។

ក៖ បាំទ!

ខ៖ តែដល់សង្គមប៉ុលពតនេះ ។

ក៖ បាំទ!

ខ៖ អានឹងខ្ញុំពិបាកកន្លែងនិងម៉ង់ ។

ក៖ មានបញ្ហាច្រើន?

ខ៖ មានបញ្ហាច្រើនណាស់ នៅសង្គមប៉ុលពតនិង។

ក៖ មីងអាចរៀបរាប់ ខ្លះៗបានទេ?

ខ៖ គឺខ្ញុំលំបាកណាស់ ពេលដែលយើងទៅ ខ្ញុំជាកងចល័តកាលជំនាន់នឹង ខ្ញុំកងចល័តពេញ ម៉ង ។

ក៖ បាទ!

ខ៖ ហើយកាលណាដែលយើង ទៅធ្វើការពេលម៉ោង៤ ឡើងពីម៉ោង៤ទៅធ្វើការ ហើយយើង បានហូប បបរតែម៉ាពោះឡូ។

ក៖ ម៉ាពោះឡូ!

ខ៖ នឹង! បើនិយាយឲ្យចំទៅ ប្រហែលជាមួយវែកណា។

ក៖ អូ!

ខ៖ ដាក់មកម៉ាពោះឡូ ប៉ុន្តែបបរនឹងខាប់ ជំនាន់និង។

ក៖ បាទ!

ខ៖ គឺនិយាយឲ្យចំទៅ គឺលំបាកមែនទែនម៉ង់ ជំនាន់ប៉ុលពតនឹងនា។

ក៖ បាទ! ចុះគេឲ្យយើងធ្វើអីខ្លះទៅមីង?

ខ៖ អូ! ទៅជីកប្រឡាយ ស្ទង់ គឺមានច្រើនយ៉ាងណាស់។ ជីកប្រឡាយ គេសែងអាបៃលៃយើង និង។

ក៖ អាបៃលៃ?

ខ៖ ស្គាល់អាបៃលៃអត់?

ក៖ ស្គាល់!

ខ៖ នឹង! ជីកប្រឡាយគឺថា ពេលម៉ោង៣ ម៉ោង៤ គឺដើបទៅហើយ ។

កៈ អ៊ូ!

ខៈ ម៉ោង៤ ម៉ោងជិតភ្លឺនេះ ។

កៈ អ៊ូ! មីង ប៉ុន្តែម៉ោងប៉ុន្មានទើបគេឲ្យយើងឈប់?

ខៈ រហូតដល់ ១១ ១២បានឈប់។

កៈ ចុះល្ងាច?

ខៈ ល្ងាច ម៉ោង១២កន្លះអីចុះទៀតហើយ ។

កៈ ដល់ម៉ោងប៉ុន្មានទៅ?

ខៈ អត់មានសំរាកទេ រហូតដល់ម៉ោង៥។

កៈ ហើយចាប់ពីនិងបានគេ ឲ្យយើងទំនេរ។

ខៈ បានឲ្យសំរាក អត់មានទំនេរទេ សំរាកម៉ោង៥និង មកដល់ញុំបបរហើយគឺយើង ហូបបបរហើយគឺយើងប្រជុំទៀត ។

កៈ ប្រជុំ?

ខៈ ប្រជុំ!

កៈ ប្រជុំដល់ម៉ោងប៉ុន្មាន?

ខៈ មេគេហៅប្រជុំណា ហៅប្រជុំនៅណោះនិយាយមិត្តសំលាញ់អីណា សព្វគ្រប់អស់ហើយមិនងាយបានដេកទេ រហូតដល់ម៉ោង១០អីណោះ។

កៈ ងាប់!

ខៈ ប៉ុន្តែកាលណោះយើង អត់មានម៉ោងមើលផងនឹង ។

ខៈ ប៉ាំទ!

ខៈ ហើយយើង អត់មានម៉ោងមើលទេ។

កៈ ចឹងអត់ដឹងថាម៉ោងប៉ុន្មានទេ?

ខៈ អត់ម៉ោងប៉ុន្មានទេ ប៉ុន្តែយូរណាស់ និយាយៗទៅប្រធានគេនិយាយទៅយើង ដេកទៅចឹងទៅណាស់។

កៈ បាទ!

ខៈ នឹងហើយ! ហើយទំរាំគេថា រំសាយយើងទះដៃ យើងមកកន្លែងមក។

កៈ ចុះពេល?

ខៈ ហើយបើខ្ញុំសំរាកនៅសាលាលោក។

កៈ បាទ!

ខៈ សាលាឆានណាស់ សាលាឆាន លោកនៅវត្តស្កុំម៉ង។ ស្កុំជើង ស្កុំត្បូងកាត់ភូមិអំពិលនឹងម៉ង ។

កៈ បាទ! ចុះយើង លក្ខណៈថាយើងជា មានលោកមានអីចឹង អត់ទេមីង?

ខៈ អត់មានលោកណា ជំនាន់នោះគ្មានលោកទេ។

កៈ ប៉ុន្តែមានវត្ត!

ខៈ វត្តគេធ្វើយូរហើយណា ។

កៈ បាទ!

ខៈ វត្តសល់ដល់ពេលនេះទៅ សម័យនិងគឺគ្មានលោកទេ ដេកនៅសាលាឆាននិងម៉ង។ នៅអត់អស់នៅសាលាឆាន ដេកនៅកុដិ។

កៈ អូ! ចុះគេមានត្រូវជំលៀកទៅណាទៀតអត់មីង? ឬមួយក៏អត់ទេ?

ខៈ ជំលៀកៗ ទៅឆ្ងាយណាស់ បើនិយាយឲ្យចំទៅដើរឆ្ងាយណាស់។ សឹងដើរម៉ងអត់មានអីជិះទេជំនាន់នឹង ដើរទៅម៉ង។

ក៖ ជំលៀកទៅណាវិញមីង?

ខ៖ ទៅ! នៅខេត្តព្រៃវែងនឹងដែល ប៉ុន្តែឃុំខុសគ្នា ហួកស្មែងពូលទៅទៀត គេហើយទាកាចំ។

ក៖ អូ! មីងនៅស្មែងពូលពីមុនត្រូវទេ?

ខ៖ នឹងហើយ! ខ្ញុំនៅខាងស្មែងពូលនិង ប៉ុន្តែខ្ញុំនៅជួរមាត់ទន្លេ គេហៅទន្លេហើយទៅ ជំលៀកទៅស្មែងពូលអីនឹង ខាងស្រែទេ។

ក៖ បាទ!

ខ៖ នឹងហើយខ្ញុំនៅខាងទន្លេតូច

ក៖ បាទ! មីង។

ខ៖ ហើយទៅកន្លែងនិងក៏វេទនាដែល ម៉ោង៣ ម៉ោង៩និងឡើងស្ងង់ហើយ។ ថាវេទនាម៉ាចប់តែនៅកំលាំងពេញអត់សូវអស់កំលាំងទេ។

ក៖ បាទ!

ខ៖ នៅកំលាំងពេញ វាកំពុងពេញកំលាំងណាកាលនឹង។

ក៖ បាទ!

ខ៖ មីងអត់មានហេវហាត់អីទេ តែបើយើងទៅនេះចឹង យើងចាប់ក្តាមចាប់អីមកហូបបាន។

ក៖ ញុំទាំងឆៅចឹងមីង?

ខ៖ អត់ទេ យើងយកមកដាក់ទឹកអំបិល ហែលៗយើងដាក់ទៅ ហើយគ្របវាទៅ។ ឲ្យតែវាងាប់ យើងអាចញុំបានហើយ និងមួយជំនាន់នឹង។

ក៖ ប៉ុន្តែ នៅពេលដែលយើងអាចទៅធ្វើស្រែ ធ្វើអីចឹងយើងអាចនៅសល់ពេលចឹង យើងអាចដើររាវក្តាម រកខ្យង រកអីចឹង?

ខ៖ កាលដែល អត់មានសល់ពេលទេ កាលដែលយើងស្ទូងៗចឹងទៅ វាចាប់បានណា។

ក៖ អូ៎! ឃើញវានៅនិង?

ខ៖ នឹងហើយ! វាឃើញ វាស្ទង់ទៅប៉ះវា ក៏ចាប់បាន។

ក៖ ទាំងខ្យង ទាំងត្រីអីនិង?

ខ៖ បាន! តែបាន តែក្ដាមមួយ និងត្រី តែយើងអត់មានអីធ្វើទេ។ មានអីយកមកធ្វើបានទេ ។

ក៖ បាទ!

ខ៖ ជំនាន់និង គឺវេទនាបំផុតម៉ងណា បើសិនជាដូចសព្វថ្ងៃនិង គឺមិនអាចរស់បានទេ។

ក៖ បាទ!

ខ៖ និងហើយ! កាលណោះយើងមាន យើងនៅមានពេញកំលាំង ហើយណាមួយយើងហូប តិចតួចក៏បាន ដែលកាលនឹង។ នៅតែមានកំលាំងចឹង ។

ក៖ ចុះយើងជំលៀកទៅភូមិមួយទៀតទៅ ហើយអ្នកមីងមានការជំលៀកទៅភូមិមួយផ្សេងទៀត ឬក៏អត់? ឬមួយទៅពីភូមិមីង ជំលៀកទៅភូមិមួយទៀតហើយ ធ្វើការចឹងដែល ហើយឈប់ជំលៀកហើយ?

ខ៖ ជំលៀកទៅនៅ នៅកន្លែងវត្តនិង។

ក៖ បាទ!

ខ៖ ផុតពីវត្តនិងទៅ គេជំលៀកទៅភូមិផ្សេងទៀត ផ្សេងទៀតនិងទៅនៅផ្ទះអ្នកស្រុក។

ក៖ ប៉ុន្តែគេឲ្យយើងធ្វើអីគេទៅមីង?

ខ៖ ស្ទង់ ដកនិង សែកតាបែឡៃនិង លើកប្រឡាយ ជីកប្រឡាយរហូតនឹង ។

ក៖ គេឲ្យយើងធ្វើអានិងរហូត?

ខ៖ ធ្វើរហូត! ខែស្ទង់យើងស្ទង់ តែមួយហិតតាស្ទង់តែ៦នាក់ទេណា។

ក៖ គេកំនត់ថ្ងៃឲ្យយើងអត់?

ខ៖ កំនត់យើង ។

ក៖ ប៉ុន្មានថ្ងៃ?

ខ៖ កំនត់យើងឲ្យហើយ មួយហិតតា៦នាក់យើងឡើងតាំងពីម៉ោង៣ទៅ មួយថ្ងៃហើយ។

ក៖ អ៊ូ!

ខ៖ មួយហិតតា កាលណោះស្ទង់ហើយណា មិនគួរឲ្យជឿទេណា។

ក៖ បាទ! ខ្លាំងណាស់។

ខ៖ ស្ទង់ហើយមែន៦នាក់គត់ ហើយខ្ញុំនិងជាទ័ពស្រួច នឹងកាលណោះធ្វើការអើក៍ខ្លាំងដែល ខ្លាំងទាំងអស់ម៉ង ឈានមុខគេម៉ងណា ។

ក៖ បាទ! ចុះតើស្រីទៅស្ទង់?

ខ៖ សុទ្ធតែស្រីៗទាំងអស់ បុរសដាក់ដោយបុរស។

ក៖ ចុះប្រុសៗ គេឲ្យធ្វើអីវិញ?

ខ៖ ប្រុសគឺនៅកន្លែងផ្សេង បុរសនិងស្ត្រីមិនអាចជួបគ្នាបានទេ សូម្បីតែបងប្អូនបង្កើតក៍ដោយ ក៍មិនអាចជួបគ្នាបានដែរ។ ខ្លាចខូចសីលធម៍។

ក៖ បាទ! មីង ចុះពេលដែលមីងបន្ទាប់ពីនៅផ្ទះអ្នកភូមិ មីងទៅណាទៀតទៅ?

ខ៖ គេឲ្យមកវីញ ដល់ធ្វើការកន្លែងនិងចប់ គេឲ្យមកនៅកន្លែងសាលាលោកនិងវិញ ។

ក៖ ឆ្នាំណាទៅមីង មីងចាំអត់?

ខ៖ អ៊ូ! អត់ដឹត អត់ចាំផង។ ហើយមកនិងណា វេទនាជាទីបំផុតដោយសារអី ដោយសារយើង អត់មានទឹក ទឹកហូបណា។

ក៖ បាទ!

ខ៖ ទឹកនិង ទៅសុំទឹកអណ្ដូងអ្នកស្រុក គេសឹងតែបិទអណ្ដូងទៀតណា គេអត់ឲ្យយើងទេ។ យើងហូបតែទឹកស្រះទេ ស្រះលោក តែអត់មានលោកទេ ផឹកទឹកស្រះនឹងល្អក់ក៏ដោយ ស្អីក៏ដោយក៏យើងហូបនៅនិងដែល ប្រើនិងហូបនិងទាំងអស់។

ក៖ បាទ!

ខ៖ បើនិយាយឲ្យចំទៅវេទនាខ្លាំងណាស់ កាលជំនាន់ប៉ុលពតនឹង។

ក៖ ចុះនៅពេលដែលដាច់ប៉ុលពត មីងធ្វើអីទៀតទៅមីង?ពេលដែល ចង់និយាយថាពេលដែល?

ខ៖ បែកប៉ុលពតហោ?

ក៖ គេមករំដោះនោះ ។

ខ៖ គេមករំដោះ បើនិយាយឲ្យចំ៣ថ្ងៃទៀតទេដែលត្រូវគេវៃចោល។ គេឲ្យយើងញុំនំបញ្ចុកហើយ ហើយហូបនំបញ្ចុកហើយៗ តែហូបនំបញ្ចុកហើយ គេយកទៅវៃចោលហើយ។ តែយើងហូបហើយៗ តែគេសន្យា៣ថ្ងៃទៀត គេបញ្ចូលយើងទៅ។

ក៖ បាទ!

ខ៖ នឹងហើយ! ប៉ុន្តែគេរំដោះមក ទើបយើងរស់នឹង។

ក៖ បាទ! ៣ថ្ងៃនឹងគេត្រូវបញ្ចូលទៅ ហើយ៣ថ្ងៃនឹងចំនៅពេលដែលគេមករំដោះ។

ខ៖ គេមកដោះ៧មករាយើងនេះ បានយើងបានរស់នឹង។

ក៖អូ!

ខ៖ នឹងហើយ! អានិងជីវប្រវត្តិចឹង។

ក៖ ចុះនៅពេលដែលអ្នកមីង នៅពេលដែលចប់ពីប៉ុលពតអ្នកមីងទៅនៅណា? ហើយមីងធ្វើអីគេ?

ខ៖ មកនៅភូមិ មកនៅភូមិ មកនៅស្រុកវិញមក ។

កៈ នៅព្រៃវែងដែរ?

ខៈ នឹង! នៅព្រៃវែងដែល នៅភូមិព្រែកកាំភ្លើងនឹង។ និងនៅ និងរហូតទៅ។

កៈ ប៉ាទ! ចុះមីងធ្វើអីគេមីង។

ខៈ មកដូចជាគ្មានធ្វើអីទេ លក់ដូរៗធម្មតានឹង កាលណោះមានអីណាដូច ដូចចេះតែរស់ដែល នឹង។

កៈ ចុះ!

ខៈ ហើយដល់នោះយើងមានកង់មួយ យើងជិះទៅលក់ទៅដូរអីចឹង។ កាលនិងទៅណាមក ណាយើងដាក់អង្ករតាម នំអស្សមអាំង អង្ករមួយកំប៉ុង កាលនិងដូរកំប៉ុងទេ។

កៈ ខោអាវអីវេចទៅ ទៅ?

ខៈ ដូចអត់មានខោអាវផង។ ខោអាវតាំងពីជំនាន់ប៉ុលពតមកនិង ។

កៈ មួយកំភ្លេនិង?

ខៈ អាខ្មៅៗនិង។ ខោអាវមួយនិង មិនផ្លាស់ប៉ុន្មានទេ អាក្រហមក៏មាន អាខ្មៅក៏មាន អាសរក៏មាន ឲ្យតែមានគឺប៉ះចឹងម៉ង់ ជំនាន់នឹង។

កៈ ប៉ាទ! ចុះឆ្នាំណាដែលមីងមកនៅភ្នំពេញវិញ?

ខៈ អេ! មកនៅភ្នំពេញវិញ ប្រហែលជាឆ្នាំ៩០។

កៈ អ៊ូ! ៩០ ចឹងមានន័យថា អំឡុងពេលជាង៨០និងរហូត មីងនៅស្រុករហូតមីង?

ខៈ នៅស្រុក។

កៈ នៅលក់ដូរ នៅលក់អីនិងទៅ។ ចុះមីង និយាយថាមីងរៀបការនៅឆ្នាំណាទៅមីង?

ខៈ ជំនាន់និង តាំងពីនេះម៉ោះណោះ ខ្ញុំរៀបការតាំងពីជំនាន់ប៉ុលពតណោះ ។

កៈ ចឹងថា មីងរៀបការតាំងពីជំនាន់ប៉ុលពត?

ខ៖ ជំនាន់ប៉ុលពត និងហើយ។

ក៖ ប៉ុន្តែ ជំនាន់ប៉ុលពតគេមិនឲ្យនៅជាមួយ ក្រុមគ្រួសារទេ?

ខ៖ ជំនាន់ប៉ុលពតគេរៀបការហើយ គេឲ្យយើងចាប់ដៃគ្នានឹង ១៥០គូរណាស់ ។

ក៖ បាទ!

ខ៖ ក្នុងមួយពេលនិង១៥០គូរ ។

ក៖ ប៉ុន្តែពេលនិងមីងអាយុប៉ុន្មានដែលមីង?

ខ៖ កាលនិងអាយុ១៩ឆ្នាំ។

ក៖ ១៩! ប៉ុន្តែចង់និយាយថា ជំនាន់ប៉ុលពតមីងប្រាប់ថា មនុស្សប្រុសគេមិនឲ្យនៅជាមួយ មនុស្សស្រីសូម្បីតែបងប្អូន?

ខ៖ អត់ទេ! អត់មាននៅជាមួយគ្នាបានទេ តែគេចាប់គូរ ដូចថាអាចាន់ជាគូរនិងបុរសផ្សេងចឹង។ អានិងងគេចាប់ចឹងម៉ង់ គេចាប់ជល់ៗម៉ង់។

ក៖ ប៉ុន្តែ។

ខ៖ បើសិនមិនពេញចិត្តអត់បានទេ គេយកទៅវៃចោល។

ក៖ ដល់ពេលយើងការហើយ គេអនុញ្ញាតឲ្យនៅជាមួយគ្នាបាន?

ខ៖ នៅជាមួយគ្នាបាន។

ក៖ អូ៎! ធ្វើការជាមួយគ្នាទៅ?

ខ៖ ការហើយបែកប៉ុលពតនឹង ដូចកាលមួយជំនាន់និង អ្នកអត់គ្រប់ការក៏ការដែល ដើម្បីឲ្យរួចខ្លួនកុំឲ្យគេសំលាប់។

ក៖ គេយកទៅវៃចោល។

ខ៖ នឹងហើយ! តែវាចៃដន្យដែល វាចៃដន្យចឹងទៅណា យើងរួចហើយអស់ចឹងទៅ វាបែក៧មក វាបានយើងរស់។ កុំអីអត់រស់ទេ ទាំងអស់គឺទាំងអស់ម៉ង់។

ក៖ ទាំងអស់គ្នាម៉ង?

ខ៖ វេទនាទាំងអស់គ្នាម៉ង។ ប៉ុន្តែគេអ្នកមានគ្រួសាររួចហើយអត់អីទេ ខ្លាចតែអ្នកនៅលីវៗ អ្នកមិនទាន់គ្រប់ការ អ្នកមិនទាន់អីចឹងគឺវេទនាទាំងអស់។

ក៖ បាទ!

ខ៖ ប៉ុនជំនាន់នឹងអត់វេទនាទេ យើងមានកំលាំងពេញ។ អត់វេទនាទេ យើងហូបបាយបានតិចមែន តែយើងនៅតែមានកំលាំងចឹង ពីព្រោះថាយើងមិនអត់ ហត់ហោរដូចរាល់ថ្ងៃចឹងណា។ នឹងហើយ! ហើយមកដល់ភ្នំពេញនេះបាន ពិបាកវេទនាកាលពីមុនមកសុខស្រួលទេ តែមកដល់ធ្លាក់ខ្លួនឈឺខ្ញុំ។

ក៖ ចុះមីងកាលមកភ្នំពេញដំបូង មីងធ្វើអីគេដែរ?

ខ៖ ទេបើនិយាយឲ្យចំខ្ញុំ លក់ដូរតែចឹង។

ក៖ មីងមកនៅភ្នំពេញដំបូង មីងមានផ្ទះខ្លួនឯងឬក៏ម៉េច?

ខ៖ អត់ទេ! ជួលគេ។ ខ្ញុំមកនៅ មកមុនដំបូលមកនៅកន្លែង សាលាបើកបរឈ្មោះសាលាបើកបរ។

ក៖ នៅណា?

ខ៖ អេ! មុនដំបូងមកនៅបន្ទាយស្លឹក ។

ក៖ បន្ទាយស្លឹក?

ខ៖ ស្គាល់បន្ទាយស្លឹកអត់?

ក៖ អត់!

ខ៖ បន្ទាយស្លឹកនៅជិតចេនឡាណោះ។

កៈ អុំ!នៅជិតចេនឡា។

ខៈ បន្ទាយស្លឹកនៅផ្សារដើមគរ និងហើយមកនៅផ្សារដើមគរ និងមកនៅចេនឡា នៅបន្ទាយស្លឹកនិងហើយ ក៏គេឲ្យខ្ញុំមកនៅសាលាបើកបរ។ សំណង់ណា កាលនឹងខ្ញុំធ្វើការសំណង់ មានកូនអស់ហើយណាស់ មានកូនច្រើននៅធ្វើការសំណង់។ មីអូនខ្ញុំនិងពោះធំហើយ នៅមកធ្វើការសំណង់មានពោះ៦ខែ ក៏មកនៅធ្វើការសំណង់ដែរ។

កៈ ឆ្នាំ៩០ជាងមែនទេ?

ខៈ នឹង! ៩០គត់ ៩១ ៩២អីនិងខ្ញុំនៅធ្វើការសំណង់តើ។ ពោះធំបាន៧ខែក៏នៅធ្វើការសំណង់ដែល ដល់តែពេលខ្ញុំកូនងែង បានមកនៅប៉ូដេញ។

កៈ អុំ! នៅប៉ូដេញ។

ខៈ នៅប៉ូដេញយើងនិង។

កៈ បាំទ!

ខៈ បានមកនៅនិង ចាប់មកនៅនិងរហូត ចាប់នៅនិងនៅរហូតម៉ង់ណា។ ដល់កូននិងបានកើតអីហើយ ក៏កូនកើត៩៣ មីអូនកើត៩៣។

កៈ ចុះពេលអ្នកមីងមកភ្នំពេញដំបូង អ្នកមីងធ្វើការសំណង់ជាមួយកូនបង?

ខៈ កូនខ្ញុំអត់សូវបានរៀនទេ កូនៗខ្ញុំអត់សូវបានរៀនទេ។

កៈ ប៉ុន្តែពួកគាត់ធ្វើអីគេទៅ?

ខៈ ទុកនៅជីដូន ។

កៈ ចុះប្តីមីងធ្វើអីគេពេលនោះ?

ខៈ កាលនោះធ្វើការសំណង់ដូចគ្នា។

កៈ អុំ! ធ្វើជាមួយគ្នានោះ។

ខៈ ចាំ!

កៈ កាលនោះប្រាក់ខែមីង ដូចជាបានប៉ុន្មានដែរមីង? វាមិនសូវច្រើនទេមែនទេ?

ខៈ ប៉ុន្មានទេពេលនឹង ដូចជា១៥,០០០ ឬ៣៥,០០០ទេជំនាន់នឹង។

កៈ តែលុយថ្លៃ?

ខៈ មួយអាទិត្យណាស់ មួយអាទិត្យបានតែ៣០,០០០ អីនឹង ២៥,០០០អីនឹង។

កៈ អូ៎!ម្នាក់នោះ?

ខៈ ម្នាក់! មួយអាទិត្យណាស់ នឹងហើយ។

កៈ ចុះនៅពេលអ្នកមីងមកប៉ូដេញ អ្នកមីងធ្វើអីគេវិញ?

ខៈ មកប៉ូដេញ ខ្ញុំចាប់... មកប៉ូដេញដូចអត់រកអីផង។

កៈ តែអ្នកមីងនៅជួលផ្ទះគេមែនទេ?

ខៈ ទេទៅនៅប៉ូដេញ ខ្ញុំទិញផ្ទះខ្ញុំទិញដី ខ្ញុំទិញដីហើយខ្ញុំធ្វើផ្ទះ។ កាលទិញដីនិង ទាហានមក វាស់ជំហានទេណា វាវាស់ជំហានខ្ញុំធ្វើផ្ទះ។

កៈ ចុះប្តីមីង កាលនោះគាត់ធ្វើអីគេទៅមីង?

ខៈ គាត់ធ្វើការសំណង់។

កៈ គាត់នៅធ្វើរហូត?

ខៈ ចាំ! គាត់ធ្វើការសំណង់ មួយខែបាន១៥,០០០អីនិង ។

កៈ រហូតដល់ពេលណាដែលមីងមក ណានៅទីនឹងមីង?

ខៈ អូ៎! អានឹងនៅប៉ូដេញយូរណាស់ខ្ញុំនៅតាំងពីមីអូនខ្ញុំកើតរហូតដល់មីអូនរៀនបានថ្នាក់ទី៧ បានញ។

កៈ អូ៎!ចិន្តា?

ខៈ នឹងហើយ ចេញពីនោះមកនៅនិង។

កៈ ចឹងនៅពេលមីងនៅប៉ូដេញនឹង មីងមានបញ្ហាអីគេខ្លះ?

ខៈ កាលនោះខ្ញុំធ្លាក់ខ្លួនឈឺ ខ្ញុំឈឺរហូតជិត១០ឆ្នាំ។ ខ្ញុំឈឺទៅពេទ្យទៅអីចឹងទៅ ឈឺនិងខ្ញុំទៅពេទ្យដោយខ្លួនឯង។

កៈ អូ៎!

ខៈ ឈឺខ្ញុំទៅពេទ្យដោយខ្លួនឯង ពីរនាក់ម៉ែកូននឹងទៅហើយ ហើយនិយាយចំទៅខ្ញុំមានប្តីដូចអត់ប្តី ។

កៈ ម៉េចចឹងមីង?

ខៈ គាត់អត់សូវមើលយើងទេ។

កៈ អូ៎!

ខៈ គាត់អត់សូវមើលយើងទេ គាត់រវល់ការងារគាត់ និយាយឲ្យចំគាត់រវល់ការងារគាត់។

កៈ តែបើគ្រាន់ថា គាត់រួចការងារគាត់ រៀបចំមើលកូនចៅមើលមីងអីទៅ។

ខៈ គាត់រួចពីការងារគាត់ផឹកហើយ គាត់អត់មើលទេ។ ដូចទៅពេទ្យឃើញស្រាប់ហើយ ខ្ញុំទៅពេទ្យលើកមុនដេក៧ថ្ងៃគាត់មកម្តងទេ តែរួចហើយស្រវឹងទៀត។

កៈ ចុះនៅពេលដែលមីង ផ្លាស់មកទីនឹងមីងមានបញ្ហាអីកើតឡើងក្នុងជីវិតមីង?

ខៈ បើនិយាយឲ្យចំទៅ វាមានកើតជំងឺនិងម៉ង ជំងឺឈឺនិងម៉ងគឺថាឲ្យយើងអស់ថវិកាអីៗ គឺថាជំងឺឈឺនិងម៉ង។ បើនិយាយឲ្យចំ ជីវិតខ្ញុំវាសព្វថ្ងៃនិង ពីមុនមកគឺខ្ញុំអត់ចង់និយាយទេ ហើយការដោយនេះខ្ញុំចិញ្ចឹមដល់ចៅមួយទៀត រាលថ្ងៃនឹងចៅកំព្រាទេ។

កៈ អូ៎! ចៅកំព្រា?

ខៈ អាធំនឹង! អាធំនឹងអាសុខហេងនិងណា។

កៈ បា៎ទ!

ខ៖ កាលនិងខ្ញុំនៅប៉ូដេញ ខ្ញុំនៅប៉ូដេញនិងខ្ញុំនិយាយកាត់។ ខ្ញុំនៅប៉ូដេញនឹង កាលនិងកូនខ្ញុំវាមានប្រពន្ធ មានប្រពន្ធវាបានមានកូន ហើយដល់មានកូនទៅវា លែងគ្នាទៅវាយកអាសុខហោងមកឲ្យខ្ញុំចិញ្ចឹម។ ចិញ្ចឹមណាខ្ញុំកំសត់ណាស់ កន្លែងនិងប្រវត្តិខ្ញុំកំសត់ណាស់។

ក៖ ប៉ាទ! កូនបងរបស់មីង?

ខ៖ កូនបងរបស់ខ្ញុំនិង អាកូនទីមួយ។ កូនប្រុសទេតែយកកូនមកឲ្យ ហើយមីស្រីនិងវាយកកូនមកឲ្យយើងណា តែពីរខែកន្លះចិញ្ចឹមវា មីងហើយនិងក្មួយ អាក្មួយនិងធំជាងម្តាយមីងទៀត។ ប្រវត្តិខ្ញុំកំសត់មែនទែន កំសត់ខ្ញុំនិងកំសត់ជាងនាងបន្ទាចារទៀត។

ក៖ ចុះកូនទីពីរ របស់មីងគាត់?

ខ៖ កាលនឹងខ្ញុំ អាទីពីរអាទីបី វានៅកន្លែងលាងឡាន លាងឡានថាខ្ញុំមិនដែលទៅយកប្រាក់ខែ។ កូនអត់ទេៗឲ្យតែវារស់តែខ្លួនវាចឹងទៅណា អត់ដែលទេអត់ដែលសោះ។

ក៖ ចុះកូនមីងប្រុសបីនាក់មែនទេ?

ខ៖ ប្រុសបីនាក់ ស្រីតែមួយទេ។

ក៖ ចុះឥលូវពួកគាត់ធ្វើអីគេទៅវិញមីង?

ខ៖ ឥលូវគេមានប្តី ប្រពន្ធអស់ហើយ គេមានការងារធ្វើគ្រប់គ្នាហើយ គេមានផ្ទះសំបែងហើយអស់  ហើយ។

ក៖ ប៉ុន្តែនៅភ្នំពេញនិងដែលឬមួយនៅ?

ខ៖ នៅតាមខេត្ត នៅឧដ្តុងណោះ អាមួយទៀតនៅគីឡូ៩នេះ។

ក៖ អូ! គីឡូ៩

ខ៖ និងហើយ ហើយមួយទៀតនៅរោងកុនគិរីរម្យ តែគេធ្វើទាហានធ្វើជាទាហានថៃសួន សួនកុមារ   និង។ សួនកុមារនៅជិតវត្តភ្នំនឹង។

ក៖ ចឹងបានន័យថា កូនចៅមីងនៅជិតៗភ្នំពេញនិងទាំងអស់គ្នា?

ខ៖ ឥលូវនឹងនៅជិតៗភ្នំពេញ មានតែមួយទេនៅឆ្ងាយ។

ក៖ អូ៎! នៅឧដ្ដុង។

ខ៖ នៅឧដ្ដុង។

ក៖ បា៎ទ!

ខ៖ ហើយខ្ញុំរាល់ថ្ងៃនិងយកតែចៅមក ចិញ្ចឹមនិងហើយចិញ្ចឹមអាមួយនឹង។

ក៖ ចុះមីងសព្វថ្ងៃ មីងនៅប៉ុន្មាននាក់ដែលមីង?

ខ៖ រាល់ថ្ងៃនិងបើឲ្យនៅចិតស្តេរទៀត តែ៥នាក់ទេ អេ៥អី ៤តា ៥ទាំងប្តីណា។ ប៉ុន្តែប្តីក៏មិនចិតថេរដែល យូរៗមកម្តង។

ក៖ ចុះមីងនៅ៥នាក់និង នៅជាមួយអ្នកណាគេខ្លះទៅ?

ខ៖ នៅជាមួយចៅ២ ហើយកូនមួយម៉ែមួយវា៤ ហើយនិងប្តីមួយទៀត។

ក៖ ចុះប្តីមីងយូរៗមកម្តង គាត់អត់មកនិងគាត់ទៅណាវិញ?

ខ៖ គាត់ទៅគេងកន្លែងគាត់ គាត់មានកន្លែងគាត់នៅ ស៊ីនៅណោះអីណោះទាំងអស់។

ក៖ គាត់ខ្ជិលមក?

ខ៖ គាត់ខ្ជិលមក។

ក៖ កន្លែងគាត់ធ្វើការឆ្ងាយទេមីង?

ខ៖ នៅកន្លែងវិមានឯករាជ្យនិង។

ក៖ អូ៎! ជិតនឹង។

ខ៖ ផ្ទះសម្តេច។

ក៖ អូ៎! គាត់ធ្វើនៅណោះ?

ខ៖ នឹងហើយ គេនៅកាន់ការងារនិង គេនៅយាមរថក្រោះ នៅណោះកន្លែងគេស៊ីនិងដេកនិង។ យើងស៊ីរស់ដោយយើងទៅ គេស៊ីដោយគេទៅ បើនិយាយឲ្យចំពិបាកណាស់ និយាយមិនកើតទេ។

ក៖ ចុះមីងនៅរាល់ថ្ងៃនិង មីងនៅធ្វើអីគេដែលលក់ដូរ?

ខ៖ លក់ដូរតិចតួចនឹង នៅផ្ទះនិងមិនដឹងធ្វើអី។

ក៖ ចុះកូនមីងចិន្តា?

ខ៖ កូននិងគាត់ធ្វើអីៗខ្លះទៅ ជូនក៏អត់ទៅ ជូនក៏បានទៅ និយាយឲ្យចំទៅអត់ច្រើនជាងបាន។ ប្រវត្តិនឹង ជីវប្រវត្តិនិងបើសិនជានិយាយឲ្យចំ កន្លែងទឹកភ្នែកហើយ ដូចចៅខ្ញុំអីនិងចៅខ្ញុំចិញ្ចឹមរហូតដល់វាធំ មិនមែនអស់តិចទេណាចៅខ្ញុំ។ ឥលូវនិងបានសំណាងហើយ រាល់ថ្ងៃខ្ញុំងាប់ខ្ញុំលែងគិតហើយ ខ្ញុំគិតតែចៅធ្វើម៉េចឲ្យមានអនាគត នៅតែកូនមួយនិងចៅទៀតនិង ងាប់ទៅបិទភ្នែកជិតហើយ។ ហើយឲ្យតែកូនមានគ្រួសារទៅ ចៅមានអនាគតមានប៉ុណ្ណឹងអីទៅ លែងគិតហើយ។ ព្រោះរាល់ថ្ងៃវាឈឺច្រើនពេក ឈឺគ្មានថ្ងៃណាស្រាក់សោះ រាល់ថ្ងៃនិងបើជាតែមួយថ្ងៃពេញនិង មិនដឹងជាល្អប៉ុណ្ណាទេរាល់ថ្ងៃនឹង វាឈឺរហូតតែម៉ង់ណា។

ក៖ បាទ!ចុះមីងនៅនិង នៅផ្ទះខ្លួនឯងមែនទេ?

ខ៖ ផ្ទះខ្លួនឯង។

ក៖ ចុះខ្ញុំលឺថាគេជិតរើផ្ទះ ខ្ញុំលឺខាងផ្ទះគេនិយាយ?

ខ៖ វា ពិតហើយ និងហើយជិតដេញហើយ ប៉ុន្តែមិនដឹងថ្ងៃណា?

ក៖ ប៉ុន្តែគេធ្វើម៉េចវិញទៅមីង នៅពេលដែលគេដេញយើង?

ខ៖ គេដេញលឺគេថា គេឲ្យជាសំណងដែល ប៉ុន្តែមិនដឹងជាគេឲ្យជាដីក៏មិនដឹង ឲ្យជាអីក៏មិនដឹង ។

ក៖ អត់ដឹងថាគេឲ្យជាលុយយើងឬថាដី?

ខ៖ ដី ប្រហែលជាបានដី។

កៈ ប៉ុន្តែគេប្រាប់បើឲ្យដី នៅណាក៏គេអត់ទាន់ប្រាប់?

ខៈ អត់ទាន់ប្រាប់ ដឹងទេតែគេថតរូប ថតអីហើយអស់ហើយ គេធ្វើសំណុំបែបបទហើយអស់ហើយ។

កៈ ទាំងអស់ម៉ងមីង?

ខៈ ទាំងអស់ម៉ង ម៉ាជួរប្រឡាយនិងទាំងអស់។

កៈ អូ៎! ប៉ុន្តែ?

ខៈ គេដីឡូ គេដោយដីឡូគេទៅ គេអត់មានប៉ះពាល់យើងទេ។ និងហើយ គឺថាគេនៅជួរ បើនិយាយឲ្យចំទៅ គេថាសំណង់អាណាធិបតីនឹង។

កៈ បាទ! មីង។

ខៈ គេហៅសំណង់បណ្តោះអាសន្នឥលូវ។

កៈ បាទ! មីង ចុះគេនិងយកកន្លែងយើងធ្វើអីគេវិញទៅមីង?

ខៈ អត់ដឹងដែល យើងអត់ដឹង។

កៈ ប៉ុន្តែមួយនិងជារដ្ឋគេយក?

កៈ រដ្ឋ!

កៈ ចុះមីងមានធ្លាក់គិតចង់ដាក់ផែនការណ៍ សំរាប់ធ្វើអីនៅពេលដែល គេរៀបចំយកផ្ទះយកអីដូចជាយកកន្លែងយើងស្នាក់នៅចឹង?

ខៈ យើង បើនិយាយឲ្យចំទៅ គេឲ្យយើងទៅណាយើងទៅនិង យើងមិនអាចប្រឆាំងបាន។

កៈ បើសិនជាគេឲ្យជាលុយយើង យើងនិងរៀបចំរកកន្លែងណានៅគួរសម?

ខៈ នឹងហើយ! បើសិនជាគេឲ្យ លុយយើងសមរម្យយើងនិងអាច រកទិញកន្លែងណាដែលយើងអាចនៅបាន។ ព្រោះឲ្យលុយតិចណាស់ ទិញមិនបានទេនៅទីក្រុងអីណោះ។

ក៖ បាទ! បើសិនជាឲ្យលុយយើង ខ្ញុំជឿថាគេឲ្យត្រឹមតិចតួច?

ខ៖ តិចតួចនិងហើយទៅទិញអីបាន។

ក៖ ដូច៤,០០០ ៥,០០០(ដុល្លារ)។

ខ៖ ៤,០០០ ៥,០០០ទៅទិញអីឥលូវ ទៅទិញត្រឹមផ្លូវមិនបានផងនិង។

ក៖ បាទ!

ខ៖ នឹងហើយ។

ក៖ ពិបាក។

ខ៖ ពិបាកណាស់ បើនិយាយឲ្យចំទៅពិបាកណាស់ ហើយនៅកន្លែងនេះស្អុយណាស់ បើនិយាយឲ្យចំទៅ។ ឲ្យយើងធ្វើម៉េច បើយើងរស់នៅកន្លែងនិងហើយ ស្អុយហើយជាធ្វើម៉េចមានតែទ្រាំទៅ។ បើនិយាយឲ្យចំទៅពិបាកណាស់ នៅទីនេះលំបាកណាស់។

ក៖ នៅទីនេះមានហេតុការណ៍អី កើតឡើងខ្លះទៅមីង? ចងនិយាយថានៅនិងមានបញ្ហាអីកើតឡើង សំរាប់ក្រុមគ្រួសារយើង?

ខ៖ ដូចអត់អីទេ! រឿងក្រុមគ្រួសារ។

ក៖ គឺថាមានគេអ្នកនៅជិតផ្ទះអី មានបញ្ហាអីកើតឡើងសំរាប់ប៉ះពាល់ដល់?

ខ៖ អត់! អូបើនិយាយឲ្យចំទៅ វាប៉ះពាល់ច្រើនដែលនិងណា ដែលថាគេនៅខាងក្រៅនិងវាដូចគេស៊ីផឹកនិយាយឲ្យចំវាស៊ីផឹក វាឈ្លោះគ្នាវារំខានដល់យើងអីចឹងនិងណា។

ក៖ បាទ!មីង។

ខ៖ នឹងវាចឹង ប៉ុន្តែកន្លែងណាក៏មានដែល។

ក៖ បាទ! ប៉ុន្តែគ្រាន់តែមានច្រើនហើយនិងតិច។

ខ៖ វាមានខ្លះដែលមិនអត់ទេ ពីមុនវាមានច្រើន ឥលូវវាអត់សូវទេ។ និងហើយពីមុនច្រើន តែឥលូវវាអត់សូវទេ វាមិនសូវឈ្លោះគ្នា។ មួយខែអីឈ្លោះគ្នា ពីរបីដងអីចឹងទៅ បើពីមុនរាល់ថ្ងៃ។

កៈ  ចុះបើសិនជា ពួកគាត់មានបញ្ហានិងកើតឡើង សំរាប់យើង យើងធ្វើម៉េចទៅសំរាប់?

ខៈ យើងមិនស្វាត់ទេ យើងទៅជួយឃាត់ទៅអី ធ្វើម៉េចកុំឲ្យរំខានដល់យើងចឹងទៅ។ យើងទៅសួរគាត់ នាំគាត់ថាកុំមាត់ ឈប់មាត់ឈប់អីចឹងទៅ បើគេស្ដាប់យើងស្ដាប់ទៅ បើគេមិនស្ដាប់យើង គេវៃគ្នាឲ្យអស់ចិត្តទៅគេឈប់ហើយ។

កៈ អ៎ូ ! យ៉ាប់។

ខៈ វាមានតែប៉ុណ្ណឹង។

កៈ ចុះសំរាប់កូនអ្នកមីង អ្នកមីងគិតថានិងរៀបចំផែនការណ៍ គាត់ម៉េចដែលសំរាប់ចិន្តា?

ខៈ កូនខ្ញុំណោះ! ខ្ញុំចេះតែរៀបចំហើយតែ សំរេចនៅលើចិត្តកូននិង។

កៈ គាត់បានរៀនចប់ហើយមែនទេ?

ខៈ រៀនចប់ហើយ។

កៈ គាត់រៀនចប់អីគេវិញ?

ខៈ រៀនខាងកែសម្ផស្ស គេមិនមែនហើយថាសំអាតការ គេហៅថាកែសម្ផស្សទេ។ រៀនចប់ធ្វើក្រចក មុខ មាត់អីនិង ហើយកែសម្ផស្សរៀនចប់ហើយ។

កៈ ចុះគាត់បានរៀននៅសាលាចប់អត់មីង?

ខៈ រៀនមួយឆ្នាំជាងណា។

កៈ អត់ទេ! គាត់រៀននៅសាលាបឋមសិក្សា ឬអនុវិទ្យាល័យអីចឹងណា?

ខៈ រៀនបានត្រឹមថ្នាក់ទី៧នឹង។

កៈ ទី ៧?

ខៈ នឹងហើយរៀនបានត្រឹមថ្នាក់ទី៧នឹង ឈប់រៀនទៅ។

កៈ មានបញ្ហាអីកើតឡើង សំរាប់គាត់ឬមួយក៏ម៉េចមីង?

ខ៖ អត់ដឹង ឲ្យទៅរៀនអត់ទៅឥលូវឈប់រៀនហើយ។

ក៖ គាត់ចង់ឈប់រៀន?

ខ៖ នឹងហើយ!

ក៖ នៅពេលណាដែលគាត់រៀនសំអាតការមួយនិង មីងគាត់រៀននៅពេលណា?

ខ៖ រៀនយូរដែលហើយនិង ឈប់ថ្នាក់ទី៧ចង់រៀនចឹងម៉ង ទើបចង់រៀនចឹងម៉ង។

ក៖ ចឹងមានន័យថាគាត់ធំហើយណោះមីង?

ខ៖ ធំហើយនិង។

ក៖ គាត់អាចធ្វើការសំរាប់ បើកសំអាតការមួយនិងបានអត់មីង?

ខ៖ បើកបានប៉ុន្តែយើងវា បើនិយាយឲ្យចំទៅគឺយើងអត់មានលុយ។ យើងទៅបើកនៅក្រៅ បើកបានតែយើងត្រូវជួលផ្ទះគេ។ ហើយបើយើងបើកបាន និងយើងអាចឲ្យថ្លៃផ្ទះគេបាន ចុះបើយើងបើកទៅវាអត់ដាច់ វាត្រូវជំពាក់គេណា។ និងហើយ ចឹងហើយបានធ្វើនៅនិងផ្ទះ បានប៉ុន្មានយើងយកប៉ុណ្ណឹងទៅ។

ក៖ ឥលូវគាត់បើកនៅផ្ទះឬគាត់អត់ធ្វើវាទេមីង?

ខ៖ បើកនៅផ្ទះ គេមកធ្វើៗទៅ។

ក៖ អូ៎! ដាច់ដែលមីង។

ខ៖ វាដាច់ភ្ញៀវហើយ កាលមុនយើងបើកមករហូតចឹងទៅ ដល់នេះយើងឈប់ យើងឈប់ទៅធ្វើការឲ្យគេ ។

ក៖ ទៅធ្វើការអីគេវិញទៅមីង?

ខ៖ ធ្វើការអានិងដែលនិង។

ក៖ អូ៎! ធ្វើការឲ្យមេយើង ដែលយើង?

ខ៖ មិនមែនទេ ធ្វើការឲ្យគេផ្សេង ដូចគេបើកចឹងណា។

ក៖ គេត្រូវការរកកូនជាង?

ខ៖ គេត្រូវការរកកូនជាង ហើយយើងទៅនិងមេជាងហើយ ទៅអីៗនិងគេប្រគល់ឲ្យយើងទាំងអស់។

ក៖ សព្វថ្ងៃនិងមីង?

ខ៖ អត់ទេ! ឥលូវឈប់ហើយ វាឈប់ហើយឥលូវ។

ក៖ ចុះចឹងគាត់នៅលក់ដូរនៅផ្ទះទៅ?

ខ៖ ឥលូវចេះតែនៅលើផ្ទះចឹងទៅ មេជាងនិងហៅទៅវិញតែអត់ទៅ។

ក៖ តែគាត់បានប្រាក់ខែច្រើនដែលតើមីង?

ខ៖ ១៥០។

ក៖ ១៥០! អូគាត់បានគួរសម។

ខ៖ អត់ទេ! បើនិយាយឲ្យចំទៅ អាខាងកែសម្ផស្សនិងអត់ថ្លៃទេ ប្រាក់ខែអត់ថ្លៃទេទៅណាក៏អត់ថ្លៃដែល។ ពីព្រោះគេចេះច្រើនណាស់ឥលូវនិង ហើយមិនដឹងជាម៉េចបានជាឈប់ទៅធ្វើនៅនិង ប្រាក់ខែ៤៥០ ធ្វើបានពីរបីខែដែលតើ។

ក៖ តែអត់ថាហេតុអីបានជាគាត់ឈប់ទេ?

ខ៖ អត់ដឹងទេ ខ្ញុំអត់ដឹងមូលហេតុអី ដល់សួរទៅថាកន្លែងនិងដាច់អាណត្តិណា។ គេហៅទៅតែអត់ទៅ

ក៖ គាត់ខ្ជិលចង់ទៅ ?

ខ៖ ដឹងម៉េច មិនដឹងចិត្តគេម៉េច មិនដឹងគេចង់អីគេ ស្រេកតែគេរាល់ថ្ងៃ បើនិយាយឲ្យខ្ញុំកំនត់ ខ្ញុំឲ្យកូនកំនត់អត់បានទេ។

ក៖ ចឹងមានន័យថា ឥលូវនិងមីងឲ្យគាត់រៀបចំអនាគតដោយខ្លួនឯង?

ខ៖ នឹងហើយ!

ក៖ គ្រាន់ថាមីងចាំជួយ ជំនួយពីក្រោយតែប៉ុណ្ណឹងទេ? ថាគាត់ត្រូវការអី គាត់ជំនាញអី អាចគិតថាគាត់អាចរៀបចំអនាគតគាត់បានខ្លួនឯង មីងចាំរូញតាមក្រោយ?

ខ៖ ថាឥលូវនេះ ឧបមាថាឥលូវខ្ញុំចង់ធ្វើអានឹងនៅកន្លែងនេះមួយ កន្លែងនេះមួយតើខ្ញុំអាចធ្វើបានអត់?

ក៖ យើងចាំ?

ខ៖ យើងចាំថា បើកូនឯងធ្វើបានធ្វើទៅ វាគ្រាន់តែប៉ុណ្ណឹង។ អូ! បើយើងអត់រៀបចំចឹង យើងថាកូនឯងធ្វើកន្លែងនេះ កូនឯងត្រូវធ្វើអានេះ ហើយបើថាចិត្តគេអត់ចង់ធ្វើ យើងម៉េចបង្ខំគេបាន។ រឿងនិងចឹង

ក៖ បាទ! មីង អរគុណច្រើនមីងដោយសារតែមីងបានរៀបរាប់ ពីប្រវត្តិមីងច្រើន។